ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១១៤ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការរៀបចំពិធីអាហារស្រាយបួស ខែរ៉ាម៉ាឌន នៃសាសនាឥស្លាមកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតគណៈកម្មការរៀបចំពិធីអាហារស្រាយបួសខែរ៉ាម៉ាឌន នៃសាសនាឥស្លាមកម្ពុជា ដែលមានសមាសភាពដូចតទៅៈ

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម **អូស្មាន ហាស្សាន់** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី | ប្រធាន |
| ២. | ឯកឧត្តម **ហ្សាការីយ៉ា អាដាម** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី | អនុប្រធានប្រចាំការ |
| ៣. | ឯកឧត្តម **ជូ គឹមឡេង** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤. | លោកជំទាវ **ជាំ ដារីនី** | រដ្ឋលេខាធិការក្រសួងការពារជាតិ | អនុប្រធាន |
| ៥. | ឯកឧត្តម **សុះ មុះសិន** | រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា | អនុប្រធាន |

| | | | |
|---|---|---|---|
| ៦. ឯកឧត្តម | **សួន ឈាងលី** | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៧. ឯកឧត្តម | **ប៊ូន លឹមហេង** | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៨. ឯកឧត្តម | **ស្វាន ម៉ាណាន** | អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៩. ឯកឧត្តម | **អ៊ីវ ផល្លី** | អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| ១០. ឯកឧត្តម | **តុប សុភ័ក** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១១. លោកជំទាវ | **យ៉យ នីតា** | អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី | សមាជិកា |
| ១២. ឯកឧត្តម | **សាន់ សាប់អី** | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ១៣. ឯកឧត្តម | **កែវ សិរីបុត្រ** | អគ្គលេខាធិការរងគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ | សមាជិក |
| ១៤. លោក | **ឯក ប៊ុនថា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | សមាជិក |
| ១៥. ឧត្តមសេនីយ៍ឯក | **ពេជ្រ ជីវ័ន** | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |
| ១៦. ឧត្តមសេនីយ៍ទោ | **ភួង ស៊ីភិន** | នាយស្នងការប្រតិបត្តិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ១៧. លោកស្រី | **ម៉ក់ វណ្ណស៊ីថា** | អភិបាលរងសាលារាជធានីភ្នំពេញ | សមាជិកា |
| ១៨. លោក | **ស៊ឹម ម៉ាត់ទោត** | សមាជិកគណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា | សមាជិក |
| ១៩. លោក | **ឡា ខ្សែ** | ជំនួយការគណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា | សមាជិក។ |

**ប្រការ២.**_

គណៈកម្មការនេះមានតួនាទីនិងភារកិច្ចដូចតទៅ៖

- សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធដើម្បីឱ្យពិធីអាហារស្រាយបួសនេះប្រព្រឹត្តទៅល្អប្រសើរ
- ពិនិត្យនិងដោះស្រាយបញ្ហាដែលទាក់ទងនឹងការរៀបចំនិងការប្រព្រឹត្តទៅនៃពិធីអាហារស្រាយបួស
- រៀបចំកិច្ចការពារសន្តិសុខនិងសណ្តាប់ធ្នាប់របស់ពិធីអាហារស្រាយបួសឱ្យបានល្អប្រសើរ
- អញ្ជើញនិងទទួលបដិសណ្ឋារកិច្ចភ្ញៀវជាតិនិងអន្តរជាតិចូលរួមពិធីអាហារស្រាយបួសនេះ
- លើកគម្រោងចំណាយសម្រាប់ពិធីអាហារស្រាយបួស
- លើកសំណើចាំបាច់ផ្សេងៗ ដែលទាក់ទងនឹងការរៀបចំពីធីអាហារស្រាយបួសជូនរាជរដ្ឋាភិបាលដើម្បីពិនិត្យនិងសម្រេច
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលការងារជូនរាជរដ្ឋាភិបាល
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**ប្រការ៣** _

គណៈកម្មការនេះអាចបង្កើតអនុគណៈកម្មការ និងក្រុមការងារជំនាញតាមការចាំបាច់។

**ប្រការ៤.-**

សមាសភាពគណៈកម្មការក្នុងប្រការ១ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

**ប្រការ៥.-**

គណៈកម្មការនេះមានសិទ្ធិប្រើត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រីសម្រាប់ដំណើរការការងាររបស់ខ្លួន។
គណៈកម្មការនេះប្រើប្រាស់កញ្ចប់ថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី និងថវិកាពីប្រភពផ្សេងៗទៀត។

**ប្រការ៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ